រាជបណ្ឌិត្យសភាកម្ពុជា

# ការអនុវត្តគោលនយោបាយសុខភាព
# សិក្សានៅកម្ពុជា ឆ្នាំ២០០៩ - ២០១៨

## School Health Policy Implementation in Cambodia

## 2009- 2018

ណាយ គឹម សុទ្ធាវី

និក្ខេបបទបណ្ឌិត

ជំនាញ៖ រដ្ឋបាលសាធារណៈ

គ្រូណែនាំ៖ បណ្ឌិត សយ រាសី

ឆ្នាំ២០២៤

# មាតិកា

ទំព័រ

ឧទ្ទិសស្នាដៃ.....i
សេចក្តីថ្លែងអំណរគុណ.....ii
អំណះអំណាង.....iv
អក្សរកាត់.....v
សទ្ទានុក្រម.....vi
មូលន័យសង្ខេបជាភាសាជាតិ.....vii
មូលន័យសង្ខេបជាភាសាអង់គ្លេស.....ix
និក្ខេបបទសង្ខេបជាភាសាជាតិ.....xi
និក្ខេបបទសង្ខេបជាភាសាអង់គ្លេស.....xix
បញ្ជីតារាង..... xxvi
បញ្ជីរូបភាព.....xxvii
អារម្ភកថា.....xxviii

## សេចក្តីផ្តើម

១- លំនាំបញ្ហានៃការស្រាវជ្រាវ.....១
២- ចំណោទបញ្ហានៃការស្រាវជ្រាវ.....៣
៣- គោលបំណងនៃការស្រាវជ្រាវ.....៣
៤- ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ.....៤
៥- វិធីសាស្ត្រនៃការស្រាវជ្រាវ.....៥
៦- សារៈសំខាន់នៃការស្រាវជ្រាវ.....៦
៧- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.....៧

## ជំពូកទី១
## ទ្រឹស្តីគោលនយោបាយស្តីពីសុខភាពសិក្សា

**១.១- សញ្ញាណទូទៅនៃគោលនយោបាយសាធារណៈ**.....១៣
១.១.១- និយមន័យ.....១៣
១.១.២- សារៈសំខាន់នៃគោលនយោបាយសាធារណៈ.....១៦
១.១.៣- ដំណាក់កាលនៃគោលនយោបាយសាធារណៈ.....១៦
១.១.៤- ការអនុវត្តគោលនយោបាយសាធារណៈ.....១៩
១.១.៥- បរិស្ថានគោលនយោបាយសាធារណៈ.....២៣
១.១.៦- បរិស្ថានគ្រប់ដណ្តប់សុខភាពសិក្សា.....២៣

**.១.២-ការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សា**..........២៤
១.២.១- កត្តាធនធានមនុស្ស..........២៥
១.២.២- កត្តាលិខិតបទដ្ឋានគតិយុត្ត..........៣០
១.២.៣- កត្តាទំនាក់ទំនង..........៣០
១.២.៤- កត្តាចូលរួមគាំទ្រ..........៣១
**១.៣- ច្បាប់និងបទដ្ឋានគតិយុត្តគាំទ្រគោលនយោបាយ**..........៣២
១.៣.១- ច្បាប់រដ្ឋធម្មនុញ្ញ..........៣២
១.៣.២- ច្បាប់ស្តីពីការអប់រំ..........៣៣
១.៣.៣- គោលនយោបាយក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ..........៣៤
១.៣.៤- ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា..........៣៥
១.៣.៥- គោលនយោបាយពាក់ព័ន្ធ..........៣៥
១.៣.៦- សូចនាករស្នូលតាមអនុវិស័យនានា..........៤១
**១.៤- គោលនយោបាយស្តីពីសុខភាពសិក្សា**..........៤៩
១.៤.១- យុទ្ធសាស្ត្រទី១: ការពិនិត្យសុខភាព..........៤៩
១.៤.២- យុទ្ធសាស្ត្រទី២: ការអប់រំសុខភាព..........៤៩
១.៤.៣- យុទ្ធសាស្ត្រទី៣: ហេដ្ឋារចនាសម្ព័ន្ធផ្នែកសុខភាព..........៤៩
១.៤.៤- យុទ្ធសាស្ត្រទី៤: ការចូលរួម..........៥០
**១.៥- ប្រវត្តិរបស់នាយកដ្ឋានសុខភាពសិក្សា**..........៥០
**១.៦- សាវតាសុខភាពសិក្សានៅកម្ពុជា**..........៥២
១.៦.១- សម័យសង្គមរាស្ត្រនិយម..........៥២
១.៦.២- សម័យសាធារណរដ្ឋខ្មែរ..........៥៣
១.៦.៣- សម័យកម្ពុជាប្រជាធិបតេយ្យ..........៥៣
១.៦.៤- សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា..........៥៤
១.៦.៥- សម័យរដ្ឋកម្ពុជា..........៥៤
១.៦.៦- សម័យព្រះរាជាណាចក្រកម្ពុជា..........៥៥

## ជំពូកទី២

## លទ្ធផលនៃការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សា

**២.១- នាយកដ្ឋានសុខភាពសិក្សានៅកម្ពុជា**..........៥៨
២.១.១- រចនាសម្ព័ន្ធគ្រប់គ្រងនាយកដ្ឋាន..........៥៨
២.១.២- វឌ្ឍនភាពការងារសុខភាពសិក្សា..........៦១
**២.២- ការអនុវត្តលើយុទ្ធសាស្ត្រទាំង៤**..........៦២
២.២.១- យុទ្ធសាស្ត្រទី១: ការពិនិត្យសុខភាព..........៦៣

២.២.២- យុទ្ធសាស្ត្រទី២: ការអប់រំសុខភាព.......................................................................៦៦
២.២.៣- យុទ្ធសាស្ត្រទី៣: ការបំពាក់សម្ភារៈរូបវន្តផ្នែកសុខភាព.......................................................៨៥
២.២.៤- យុទ្ធសាស្ត្រទី៤: ការចូលរួមគាំទ្រ...................................................................................៩០
**២.៣- ការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សាតាមអនុវិស័យ**..៩០
២.៣.១- អនុវិស័យអប់រំកុមារតូច...............................................................................................៩០
២.៣.២- អនុវិស័យបឋមសិក្សា...................................................................................................៩៤
២.៣.៣- អនុវិស័យមធ្យមសិក្សានិងអប់រំបច្ចេកទេស.....................................................................១០៦
២.៣.៤- អនុវិស័យយុវជន.........................................................................................................១១២
២.៣.៥- អនុវិស័យអប់រំកាយនិងកីឡា.........................................................................................១១៣
**២.៤- ការវិភាគលទ្ធផលអំពីយន្តការអនុវត្ត**..............................................................១១៥
២.៤.១- ការផ្តល់សេវាសុខភាពចាំបាច់.......................................................................................១១៦
២.៤.២- ការផ្តល់សេវាអប់រំសុខភាព...........................................................................................១១៨
២.៤.៣- ប្រភពថវិកា..................................................................................................................១២០
២.៤.៤- ការលើកកម្ពស់បរិស្ថាន.................................................................................................១២១
២.៤.៥- ការលើកកម្ពស់សម្ភារៈរូបវន្តផ្នែកអនាម័យ......................................................................១២២
២.៤.៦- ប្រព័ន្ធពិនិត្យតាមដាន...................................................................................................១២៣
២.៤.៧- ការលើកកម្ពស់សុខភាពនៅតាមសាលារៀន.....................................................................១២៤
២.៤.៨- យន្តការចូលរួមពីអ្នកពាក់ព័ន្ធ ......................................................................................១២៤
២.៤.៩- ភាពខ្លាំងក្នុងការអនុវត្តគោលនយោបាយសុខភាពសិក្សា.....................................................១២៧
២.៤.១០- បញ្ហាប្រឈមនឹងការអនុវត្តគោលនយោបាយ...................................................................១២៩

## ជំពូកទី៣

## កត្តាជះឥទ្ធិពលលើការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សា

**៣.១- ការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សា**..........................................១៣២
៣.១.១- ការគាំទ្ររបស់ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា.......................................................១៣២
៣.១.២- រចនាសម្ព័ន្ធការគ្រប់គ្រងនាយកដ្ឋានសុខភាពសិក្សា.............................................................១៣៣
៣.១.៣- អនុវិស័យជំនាញចូលរួមអនុវត្តគោលនយោបាយ..............................................................១៣៣
៣.១.៤- ការដាក់បញ្ចូលមុខវិជ្ជាអប់រំសុខភាពទៅក្នុងកម្មវិធីសិក្សាជាតិ.............................................១៣៦
៣.១.៥- ការអប់រំអនាម័យនិងបរិស្ថាន.........................................................................................១៣៨
៣.១.៦- ការគ្រប់គ្រងកាកសំណល់..............................................................................................១៤០
៣.១.៧- ការរៀបចំបង្គន់អនាម័យ................................................................................................១៤១
៣.១.៨- ធនធានមនុស្សជំនាញផ្នែកសុខភាពសិក្សា..........................................................................១៤២
៣.១.៩- ថវិកាដើម្បីគាំទ្រគោលនយោបាយស្តីពីសុខភាពសិក្សា .........................................................១៤៣

៣.១.១០- សម្ភារៈរូបវន្តផ្នែកសុខភាព...................................................................................១៤៤
៣.១.១១- ការផ្សព្វផ្សាយគោលនយោបាយដល់អ្នកពាក់ព័ន្ធ.............................................................១៤៥
៣.១.១២- ការចូលរួមសហការពីសហគមន៍និងមាតាបិតាសិស្ស........................................................១៤៥
**៣.២-ដំណោះស្រាយការអនុវត្តគោលនយោបាយស្ដីពីសុខភាពសិក្សា**១៤៦
៣.២.១- ការអភិវឌ្ឍធនធានមនុស្ស...............................................................................................១៤៦
៣.២.២- ការអភិវឌ្ឍលិខិតបទដ្ឋានគតិយុត្តនិងយន្តការ.....................................................................១៤៩
៣.២.៣-ការទំនាក់ទំនង..................................................................................................................១៥១
៣.២.៤- ការចូលរួមលើកកម្ពស់ការផ្ដល់សេវាថែទាំសុខភាពចាំបាច់...................................................១៥២
**សេចក្ដីសន្និដ្ឋាន និងអនុសាសន៍**
សេចក្ដីសន្និដ្ឋាន...........................................................................................................................១៥៤
អនុសាសន៍...................................................................................................................................១៥៦

**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# ឧទ្ទិសស្នាដៃ

នាងខ្ញុំ **ឆាយ គីម សុទ្ធាវី** ជាបេក្ខជនបណ្ឌិត ជំនាញរដ្ឋបាលសាធារណៈជំនាន់ទី២ វគ្គទី១ នៃរាជបណ្ឌិត្យសភាកម្ពុជា។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះលោកឪពុក**ឆាយ គីម** និងអ្នកម្តាយ **ស្រី លន** ជាអ្នកមានគុណដែលបានផ្តល់កំណើតឱ្យកូន និងចិញ្ចឹមបីបាច់ ថែរក្សារូបកូន ទំនុកបម្រុងកូន គាំទ្រ ផ្តល់ការលើកទឹកចិត្តកូនគ្រប់បែបយ៉ាង ឱ្យកូនខិតខំរៀនសូត្រ និងផ្តល់ការស្រឡាញ់ ជារៀងរហូតមក ថ្វីដ្បិតតែ អ្នកមានគុណទាំងពីរបានលាចាកលោកក៏ពិតមែន តែគុណតម្លៃរបស់លោកអ្នកមានគុណ ទាំងទ្វេរ ធំជាង មេឃ ធំជាងផែនដី និងជ្រៅជាងមហាសមុទ្រ ពុំមានអ្វីមកប្រៀបផ្ទឹមបានឡើយ សម្រាប់កូននិងចៅគ្រប់ជំនាន់ ហើយដួងព្រលឹងរបស់លោក បេះដូងរបស់លោកតែងតែមានរូបកូន និងចៅជានិច្ច លោកនៅតែស្រឡាញ់និងតាមថែរក្សា កូននិងចៅជាដរាប។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធវីរព្រះមហាក្សត្រខ្មែរ គ្រប់សម័យកាល ដែលព្រះអង្គបានធ្វើព្រះរាជបូជនីយកិច្ច ដើម្បីបុព្វហេតុជាតិនិងមាតុភូមិ។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះវិញ្ញាណក្ខន្ធមេដឹកនាំខ្មែរគ្រប់សម័យកាល ដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិ ប្រជាជន និងទឹកដី។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះលោកគ្រូ អ្នកគ្រូ ដែលបានចំណាយពេលវេលា ដ៏មានតម្លៃមកបង្ហាត់បង្រៀនដល់រូបខ្ញុំ ក្នុងការសិក្សានៅគ្រប់កម្រិតថ្នាក់ និងការសរសេរនិក្ខេបបទនេះ។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះអ្នកសិក្សាគ្រប់ជំនាន់ ដែលបានចំណាយពេលវេលា សម្ភារៈ និងទ្រព្យធន ក្នុងការចងក្រងឯកសារនានា ទុកសម្រាប់កូនចៅជំនាន់ក្រោយ បានសិក្សារៀនសូត្រ។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះវិញ្ញាណក្ខន្ធយុទ្ធជន យុទ្ធនារី កុលបុត្រ កុលធីតា និងជនរួមជាតិខ្មែរគ្រប់រូប ពុទ្ធបរិស័ទខ្មែរ និងជនស្នេហាជាតិទាំងអស់ ដែលបានធ្វើពលិកម្ម នៅគ្រប់សម័យកាល ដើម្បីបុព្វហេតុជាតិ មាតុភូមិ និងប្រជាពលរដ្ឋរបស់យើងទាំងអស់គ្នា។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះពុទ្ធបរិស័ទខ្មែរ និងជនស្នេហាជាតិទាំងអស់ ដែលបាន លះបង់ ធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីបុព្វហេតុជាតិមាតុភូមិ។

សូមឱ្យមាតុភូមិកម្ពុជា ស្ថិតនៅគង់វង្ស មានភាពរុងរឿងសម្បូរសប្បាយ មានភាពថ្លៃថ្នូរ និង ថ្កុំថ្កើងតរៀងទៅ។

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានបង្កើត ដឹកនាំ និងគាំទ្រ ដំណើរការស្ថាប័នរាជបណ្ឌិត្យសភាកម្ពុជា ក្នុងបំណងបណ្ដុះបណ្ដាលធនធានមនុស្សប្រកបដោយចំណេះដឹងខ្ពស់ ពិសេសលើជំនាញទន់ សម្រាប់អភិវឌ្ឍប្រទេសជាតិ។

រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានបន្តដឹកនាំ និងគាំទ្រ ដំណើរការស្ថាប័នរាជបណ្ឌិត្យសភាកម្ពុជា និងបន្តការបណ្ដុះបណ្ដាលធនធានមនុស្សប្រកបដោយសមត្ថភាពខ្ពស់លើគ្រប់ជំនាញ ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិ និងជួយជំរុញប្រទេសកម្ពុជាឱ្យមានស្ថិរភាពនិងសុខសន្តិភាព។

ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដែលបានចំណាយពេលមានតម្លៃ ជួយផ្ដល់គំនិតល្អៗ អនុសាសន៍ល្អៗ និងមានតម្លៃបំផុត តម្រង់ទិសក្នុងការសរសេរនិក្ខេបបទនេះ។

ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីនៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានលើកទឹកចិត្ត និងជំរុញគាំទ្រនិងផ្ដល់ឱកាសឱ្យនាងខ្ញុំបានសិក្សារៀនសូត្របន្ត និងរៀនសូត្រពេញមួយជីវិត ដើម្បីបានក្លាយទៅជាធនធានដ៏ល្អសម្រាប់អភិវឌ្ឍប្រទេសជាតិ។

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **សយ រាសី** ជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរនិក្ខេបបទរបស់នាងខ្ញុំ ដែលឯកឧត្តមបានចំណាយពេលវេលាដ៏មានតម្លៃ និងយកអស់កម្លាំងកាយ កម្លាំងចិត្ត ផ្ដល់ប្រឹក្សា ពន្យល់ ណែនាំនិងផ្ដល់នូវអនុសាសន៍ល្អៗ និងលើកទឹកចិត្តដល់នាងខ្ញុំ តាំងពីពេលចាប់ផ្ដើមរហូតដល់ដំណាក់កាលការពារបញ្ចប់ថ្នាក់បណ្ឌិតនេះ។

នាងខ្ញុំក៏សូមគោរពអរគុណជូនចំពោះលោកសាស្ត្រាចារ្យបណ្ឌិត **សឿន សោភ័ណ** ប្រធានគណៈកម្មការការពារនិក្ខេបបទនាងខ្ញុំ ចំពោះការសរសើរលើកទឹកចិត្ត ផ្ដល់ជំបូន្មានដ៏មានតម្លៃ មិនអាចកាត់ថ្លៃបាន និងបានផ្ដល់នូវអនុសាសន៍ល្អៗ ប្រកបដោយគតិបណ្ឌិតដ៏ថ្លៃថ្លា តម្រង់ទិសក្នុងការសរសេរនិក្ខេបបទនេះឱ្យមានលក្ខណៈសុក្រឹត។

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **អ៊ុំ ប៉ុម** សមាជិកគណៈកម្មការការពារនិក្ខេបបទ ដែលបានចំណាយពេលដ៏មានតម្លៃ លើកទឹកចិត្ត បង្ហាត់ បង្រៀន វាយតម្លៃប្រកបដោយគតិបណ្ឌិត និងផ្ដល់អនុសាសន៍ណែនាំដ៏មានតម្លៃបំផុត សម្រាប់ការជួយកែនិងតម្រង់ទិស ក្នុងការសរសេរនិក្ខេបបទរបស់នាងខ្ញុំឱ្យមានគុណភាពខ្ពស់។

លោកសាស្ត្រាចារ្យបណ្ឌិត **ឆាម រតនៈ** សមាជិកគណៈកម្មការការពារនិក្ខេបបទ ដែលបាន ចំណាយពេលដ៏មានតម្លៃ គាំទ្រ និងបានវាយតម្លៃប្រកបដោយគតិបណ្ឌិត និងផ្តល់អនុសាសន៍ល្អៗ តម្រង់ទិស ក្នុងការសរសេរនិក្ខេបបទរបស់នាងខ្ញុំ ឱ្យមានលក្ខណៈបែបវិទ្យាសាស្ត្រ។

លោកសាស្ត្រាចារ្យបណ្ឌិត **អ៊ុក ទុំ** សមាជិកគណៈកម្មការការពារនិក្ខេបបទ ដែលបាន ចំណាយពេលដ៏មានតម្លៃ គាំទ្រ វាយតម្លៃប្រកបដោយគតិបណ្ឌិត និងផ្តួចផ្តើមនូវគំនិតល្អៗ តម្រង់ទិស ក្នុងការសរសេរនិក្ខេបបទនេះ ឱ្យមានលក្ខណៈវិទ្យាសាស្ត្រ និងមានលក្ខណៈជាប្រព័ន្ធ។

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ម៉ាន់ ច័ន្ទតារា** សមាជិកគណៈកម្មការការពារនិក្ខេបបទ ដែល បាន ចំណាយពេលដ៏មានតម្លៃ គាំទ្រ វាយតម្លៃប្រកបដោយគតិបណ្ឌិត និងផ្តល់នូវគំនិតល្អៗ តម្រង់ទិស ក្នុងការសរសេរនិក្ខេបបទនាងខ្ញុំឱ្យមានលក្ខណៈកាន់តែប្រសើរឡើង។

លោកបណ្ឌិត **សាន សុរាចនិត** ប្រធានកម្មវិធីបណ្តុះបណ្តាល នៃរាជបណ្ឌិត្យសភាកម្ពុជា លោកបណ្ឌិត **សេង មាន** និងលោកបណ្ឌិត **ហេង ហុកចេន** ដែលបានណែនាំ កែលម្អ និងផ្តល់នូវ គំនិតល្អ តម្រូវតាមទម្រង់នៃការសរសេរនិក្ខេបបទរបស់រាជបណ្ឌិត្យសភាកម្ពុជា តាំងពីដើមរហូតដល់ការ ការពារបញ្ចប់។ នាងខ្ញុំក៏សូមថ្លែងនូវអំណរគុណចំពោះលោកបណ្ឌិត **ទ្រី ចាន់** និងវិទ្យាស្ថានជាតិ ភាសាខ្មែរ និងមន្ត្រីនៃរាជបណ្ឌិត្យសភាកម្ពុជាទាំងអស់ ដែលបានគាំទ្រនូវរាល់តម្រូវការចាំបាច់ រាល់ភាព ខ្វះខាត ដើម្បីឱ្យនិក្ខេបបទរបស់នាងខ្ញុំ មានលក្ខណៈកាន់តែល្អប្រសើរឡើងនិងមានគុណភាពខ្ពស់។

លោកគ្រូ អ្នកគ្រូ ដែលបានយកអស់កម្លាំងកាយចិត្ត ខិតខំបង្ហាត់បង្រៀន និងបានចំណាយ ពេលវេលាដ៏មានតម្លៃចំពោះនាងខ្ញុំ ក្នុងការសិក្សា និងការសរសេរនិក្ខេបបទនេះ។

ឯកឧត្តម លោកជំទាវ លោក លោកស្រីបណ្ឌិតទាំងអស់ ដែលបានចំណាយពេលវេលាដ៏មាន តម្លៃនិងយកអស់នូវកម្លាំងកាយចិត្តបង្ហាត់បង្រៀន ជ្រោមជ្រែងក្នុងការសរសេរនិក្ខេបបទរបស់នាងខ្ញុំ។

លោក លោកស្រី តំណាងក្រសួង នាយកដ្ឋានពាក់ព័ន្ធ នាយកដ្ឋានសុខភាពសិក្សា មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំយុវជននិងកីឡា និងលោកគ្រូ អ្នកគ្រូ តំណាងថ្នាក់ក្រោមជាតិ អង្គការដៃគូពាក់ព័ន្ធទាំងអស់ ដែលបានលើកទឹកចិត្ត ចូលរួមឆ្លើយនឹងសំណួរនានា និងផ្តល់ឯកសារ ជាមូលដ្ឋាន សម្រាប់ការសិក្សាស្រាវជ្រាវ ប្រកបដោយភាពរលូន។

បងប្អូនប្រុសស្រីទាំងអស់ ជាពិសេសដល់ស្វាមី **ហ៊ឹម សូឡី** កូនប្រុសស្រីនិងចៅ ជាទីស្រឡាញ់ ដែលបានគាំទ្រនិងផ្តល់កម្លាំងចិត្តដល់រូបនាងខ្ញុំតាំងពីដើមរៀងមក។

សូមបួងសួងដល់វត្ថុសក្តិសិទ្ធិក្នុងលោក តាមជួយថែរក្សា សម្តេច ឯកឧត្តម លោកជំទាវ បណ្ឌិត-សភាចារ្យ សាស្ត្រាចារ្យបណ្ឌិត លោកគ្រូ អ្នកគ្រូ លោក លោកស្រី ឱ្យមានសុខភាពល្អ កម្លាំងមាំមួន ដើម្បី បន្តដឹកនាំនិងបណ្តុះបណ្តាលកូនខ្មែរជំនាន់ក្រោយឱ្យ ក្លាយជាធនធានមនុស្សពិតប្រាកដរបស់ជាតិខ្មែរ។

# អំណះអំណាង

នាងខ្ញុំសូមអះអាងដោយក្តីមោទនៈភាព និងទទួលខុសត្រូវខ្ពស់លើខ្លឹមសារនៃនិក្ខេបបទនេះ ថាពិតជាស្នាដៃស្រាវជ្រាវអស់ពីកម្លាំងកាយ កម្លាំងចិត្ត និងកម្លាំងប្រាជ្ញារបស់នាងខ្ញុំតែមួយគត់ ដោយគ្មានជាប់ពាក់ព័ន្ធជាមួយអ្នកដទៃឡើយ។

លទ្ធផលនៃការស្រាវជ្រាវ ដែលមាននៅក្នុងនិក្ខេបបទនេះ គឺពិតជាបានមកពីស្មារតីខិតខំប្រឹងប្រែងស្រាវជ្រាវចងក្រងពីឯកសារផ្សេងៗ និងការចុះទៅសម្ភាសផ្ទាល់ជាមួយថ្នាក់ដឹកនាំ មន្ត្រីថ្នាក់កណ្តាល មន្ទីរអប់រំ យុវជននិងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ លោកគ្រូ អ្នកគ្រូ និងដៃគូអភិវឌ្ឍពាក់ព័ន្ធមួយចំនួន។ ព័ត៌មានដែលទទួលបានពីកិច្ចសម្ភាសន៍ទាំងនោះគ្មានចម្លងចេញពីនិក្ខេបបទអ្នកដទៃឡើយ។

ថ្ងៃ អង្គារ ១៥កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ មេសា ឆ្នាំ២០២៤

ហត្ថលេខា

**នាយ គឹម សុធ្ទាវី**

**បានឃើញនិងឯកភាព**

ថ្ងៃចន្ទ ៦រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៩ខែ មេសា ឆ្នាំ២០២៤

**សាស្ត្រាចារ្យណែនាំ**

**បណ្ឌិត សយ រាសី**

# អក្សរកាត់

| | |
|---|---|
| BRIDEN HOLDEN | អង្គការស្តារគំហើញភ្នែក |
| DOEs | ការិយាល័យអប់រំ យុវជន និងកីឡា |
| ESC- BORDA CAMBODIA | អង្គការអនាម័យដើម្បីបរិស្ថានកម្ពុជា |
| EMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| FHF | មូលនិធិហ្វ្រេតហូឡូ |
| FIDR | មូលនិធិសម្រាប់ការអភិវឌ្ឍនិងជំនួយសង្គ្រោះអន្តរជាតិ |
| GIZ | អង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ |
| JICA | ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| KOIKA | ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ |
| MOEYS | ក្រសួងអប់រំ យុវជននិងកីឡា |
| MOH | ក្រសួងសុខាភិបាល |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| POEs | មន្ទីរអប់រំ យុវជននិងកីឡា |
| PISA-D | កម្មវិធីអន្តរជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស |
| RHAC | សមាគមថែទាំសុខភាពគ្រួសារ |
| SHD | នាយកដ្ឋានសុខភាពសិក្សា |
| UNFPA | អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន |
| UNICEF | អង្គការមូលនិធិសហប្រជាជាតិសម្រាប់កុមារ |
| UNILIVER and CALGET CAMPANY | ក្រុមហ៊ុនយូនីលីវើ និងក្រុមហ៊ុនខលហ្គេត |
| WASH | ទឹកស្អាតនិងអនាម័យ |
| WV | អង្គការទស្សនៈពិភពលោក |
| WB | ធនាគារពិភពលោក |
| WFP | អង្គការស្បៀងអាហារពិភពលោក |
| WHO | អង្គការសុខភាពពិភពលោក |
| WinS | ទឹកស្អាតនិងអនាម័យតាមសាលារៀន |

# សទ្ទានុក្រម

**សុខភាព** សំដៅដល់ភាពពេញលេញ ទាំងកាយ ចិត្ត និងសង្គម ដោយមិនគ្រាន់តែ មិនមានភាពពិការភាព និងជំងឺនោះទេ។

**សុខភាពបឋម** សំដៅដល់ការថែទាំសុខភាពជាសារវន្ត ដោយឈរលើវិធីសាស្ត្រ ព្រមទាំងឈរលើវិធី និងបច្ចេកទេសនានា ដែលសង្គមអាចទទួលយកបាន ឬសំដៅលើការថែទាំ សុខភាពទូទៅ ដែលអាចដំណើរការបានជាសកលសម្រាប់បុគ្គលម្នាក់ ក្រុមគ្រួសារ និងសហគមន៍ដែលមាន ដូចជាបញ្ហាខ្សោយគំហើញ ខ្សោយកម្លាំងឮ ការវាស់កម្ពស់ និងថ្លឹងទម្ងន់អ្នកសិក្សា ជាដើម។

**សុខភាពចាំបាច់** សំដៅដល់សកម្មភាពពិនិត្យសុខភាពនិងកាយសម្បទា សង្គ្រោះបឋម ចាក់ថ្នាំបង្ការ ផ្តល់ថ្នាំទម្លាក់ព្រូន ផ្តល់វីតាមីនអា ផ្តល់អាហារពេលព្រឹក និងសុខភាពមាត់ធ្មេញ។

**សុខភាពសិក្សា** សំដៅដល់សំណុំសកម្មភាពផ្សេងៗ សម្រាប់លើកកម្ពស់សុខភាព នៅតាមគ្រឹះស្ថានសិក្សា ដែលជាសេចក្តីត្រូវការជាមូលដ្ឋាននៃផ្លូវកាយ ផ្លូវចិត្តនិងសង្គមរបស់អ្នកសិក្សានិងបុគ្គលិកអប់រំ។

**បរិយាបន្ន** សំដៅដល់ការរួមបញ្ចូលគ្នានៃការផ្តល់សេវា ការប្រើប្រាស់សេវានានា នៅតាមគ្រឹះស្ថានសិក្សា សម្រាប់មនុស្សគ្រប់រូប ដោយមិនគិតពីពិការភាព ឋានៈ យេនឌ័រ ពណ៌សម្បុរ ជាតិសាសន៍ ស្ថានភាពនិងជីវភាពគ្រួសារ។

**បុគ្គលិកអប់រំ** សំដៅដល់មន្ត្រីដែលកំពុងបម្រើការក្នុងវិស័យអប់រំនិងបានបណ្តុះបណ្តាលគរុកោសល្យទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំ និងសាស្ត្រាចារ្យដែលបម្រើការនៅឧត្តមសិក្សា។ បុគ្គលិកអប់រំ រួមមានបុគ្គលិកដែលបង្រៀន និងមិនបង្រៀន ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ បុគ្គលិក ដែល បម្រើការក្នុងវិស័យឯកជនគ្រប់លំដាប់ថ្នាក់ លើកលែងតែមន្ត្រីនយោបាយ ដែលកំពុងដឹកនាំវិស័យអប់រំ ក្នុងក្រសួងស្ថាប័នរដ្ឋ។

**អ្នកសិក្សា** សំដៅដល់អ្នកកំពុងទទួលយកសេវាអប់រំអ្វីមួយ ក្នុងការបង្កើនចំណេះដឹងទូទៅ ចំណេះ និងវិជ្ជាជីវៈនានា។

**កម្មវិធីសិក្សា** សំដៅដល់សំណុំមុខវិជ្ជា ដែលត្រូវបានរៀបចំឱ្យអ្នកសិក្សា ទទួលបាននូវ ចំណេះដឹង ចំណេះធ្វើ សីលធម៌ និងសមត្ថភាពបន្តការសិក្សាពេញមួយជីវិត។

**បរិស្ថានសិក្សា** សំដៅដល់អ្វីៗទាំងអស់ ដែលមាននៅក្នុងបរិវេណ និងជុំវិញគ្រឹះស្ថានសិក្សា ដូចជាអគារសិក្សា បន្ទប់រៀន កន្លែងលក់ដូរ របង សម្ភារៈរូបវន្តផ្នែកទឹកស្អាតនិងអនាម័យ សម្ភារៈសិក្សា សួនច្បារ សួនបន្លែ រុក្ខជាតិ ជាដើម។

# មូលន័យសង្ខេបជាភាសាជាតិ

អនុវត្តតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់អប់រំ និងដើម្បីឆ្លើយតបទៅសាកលភាវូបនីយកម្ម ការកសាងធនធានមនុស្សឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងការចេះរួមរស់នៅក្នុងសង្គម គោលនយោបាយស្តីពីសុខភាពសិក្សា គឺជាមូលដ្ឋានគ្រឹះ និងចាំបាច់បំផុតសម្រាប់អ្នកសិក្សានិងបុគ្គលិកអប់រំ ដែលតម្រូវឱ្យមានការចូលរួមជាពហុវិស័យពាក់ព័ន្ធប្រកបដោយសង្គតិភាព និងអាចអនុវត្តបានក្នុងការចូលរួមអភិវឌ្ឍមូលធនមនុស្ស ដែលជាបំណងប្រាថ្នាដ៏ទទូចរបស់ប្រជាជនខ្មែរ ដើម្បីកសាងប្រទេសកម្ពុជាឱ្យទៅជាអរិយប្រទេសនាពេលអនាគត។

នៅក្នុងការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សា បានផ្តល់នូវគុណប្រយោជន៍យ៉ាងច្រើនទៅដល់អ្នកសិក្សានិងបុគ្គលិកអប់រំ ឱ្យមានសុខភាពល្អ ទាំងផ្លូវកាយ និងផ្លូវចិត្ត ដោយបានពង្រឹងការយល់ដឹងអំពីបញ្ហាសុខភាព លើកកម្ពស់សុខភាពអ្នកសិក្សានិងបុគ្គលិកអប់រំ ធ្វើឱ្យការសិក្សានិងការបំពេញការងារ ប្រកបដោយភាពជោគជ័យ។ ការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាព បានចូលរួមចំណែកចម្បងនៅក្នុងការកសាងបាននូវមូលធនមនុស្ស ដែលមានចំណេះដឹង និងជំនាញច្បាស់លាស់ សុខភាពរឹងមាំ ចំណេញថវិកា ចំណេញពេលវេលា និងធ្វើឱ្យមានសេចក្តីសុខសុភមង្គល សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ និងសង្គមជាតិ។ ការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សា បានចូលរួមគាំទ្រទាំងថវិកានិងបច្ចេកទេស ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងការលើកកម្ពស់និងទទួលបានសេវាអប់រំសុខភាព ប្រកបដោយសមធម៌និងបរិយាបន្ន ។

ទោះបីជាមានកិច្ចប្រឹងប្រែងក្នុងការលើកកម្ពស់សុខភាពសិក្សា ដូចបានរៀបរាប់ខាងលើក្តី ក៏ការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សា មិនទាន់មានភាពគ្រប់ជ្រុងជ្រោយពេញលេញ ដោយសារតែមានការខ្វះខាតនូវធនធានមនុស្សផ្នែកសុខភាពសិក្សា ឯកសារគតិយុត្ត ធនធានសម្ភារៈ ធនធានថវិកា ការមានទំនាក់ទំនងល្អ ការផ្សព្វផ្សាយ និងជាពិសេសមិនទាន់ទទួលបានការចូលរួមផុលផុសពីស្ថាប័នពាក់ព័ន្ធនៅឡើយទេ។

ឆ្លើយតបនឹងបញ្ហានេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំគោលនយោបាយ និងផែនការសកម្មភាពជាច្រើននៅក្នុងការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សា ដែលតម្រូវឱ្យមានការចូលរួមពីពហុវិស័យប្រកបដោយសង្គតិភាព អភិវឌ្ឍឯកសារគតិយុត្ត រៀបចំគម្រោង សម្រាប់លើកកម្ពស់សុខភាពសិក្សានៅតាមគ្រឹះស្ថាន

សិក្សា រៀបចំហេដ្ឋារចនាសម្ព័ន្ធផ្នែកសុខភាព រៀបចំជាសាលារៀនគំរូផ្នែកសុខភាព អនាម័យនិងបរិស្ថាន កសាងនូវមូលធនមនុស្សផ្នែកសុខភាព ផ្តល់កញ្ចប់ថវិកាឱ្យបានច្រើន តាមរយៈការកៀរគរ ឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ គ្រប់ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន លោកគ្រូ អ្នកគ្រូ មាតាបិតាសិស្ស សិស្សានុសិស្សនិងសហគមន៍ក្នុងបរិបទសាលាកុមារមេត្រី។ ការចូលរួមឧបត្ថម្ភគាំទ្រ គឺជាការងារសំខាន់ដើម្បីឱ្យគម្រោងផែនការសកម្មភាពអាចដំណើរការទៅបាន និងចាត់ទុកការងារសុខភាពសិក្សា គឺជាការងារអាទិភាពមួយនៅក្នុងអង្គភាពរៀងៗខ្លួន តែក៏សំខាន់ណាស់ដែរ ចំពោះការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងការអនុវត្តការងារសុខភាពសិក្សា ឱ្យបានជាប់ជាប្រចាំនិងគ្រប់ពេលវេលា ដើម្បីជានារួមចំណែកធ្វើឱ្យបរិស្ថានសាលារៀនមានអនាម័យប្រកបដោយសុវត្ថិភាព និងផ្តល់សិទ្ធិស្មើគ្នា ក្នុងការទទួលបាននូវសេវាថែទាំសុខភាព ចំពោះសិស្សានុសិស្ស និស្សិត បុគ្គលិកសិក្សាគ្រប់រូប ដោយផ្អែកលើផែនការដ៏ប្រសើរមួយ សម្រាប់សកម្មភាពត្រួតពិនិត្យសក្តានុពលសុខភាព។ ដើម្បីឱ្យប្រជាពលរដ្ឋទាំងអស់បានក្លាយជាពលរដ្ឋពេញលេញ មានសុខភាពល្អទាំងផ្លូវកាយ ផ្លូវចិត្ត និងសង្គម ការកែប្រែទម្លាប់ក្នុងការរស់នៅប្រចាំថ្ងៃ តាមរយៈការហូបស្អាត ផឹកស្អាតនិងរស់នៅស្អាត គឺជាវិធានការដែលត្រូវប្រកាន់យក និងអនុវត្តនូវគោលការណ៍សុខភាព អនាម័យ និងបរិស្ថានជាទីមេត្រី នៅគ្រប់ទីកន្លែងមិនថាសាលារៀន កន្លែងធ្វើការ និងលំនៅឋានប្រកបដោយនិរន្តរភាព។

## Abstract

In accordance with the Constitutional Law of the Kingdom of Cambodia, Education Law, and in response to the globalization, the development of human resource with knowledge, skills and attitudes has always been important. The National Policy on School Health, which is a foundation for educational personnel and learners, requires multi-sector involvement in order to take part in developing human capital to meet the people's needs and to boost the development of the country.

The implementation of School Health Policy has benefited learners and educational staff in terms of both mental and physical health by enhancing understanding on health issues and bringing about successful job performance. Effective and quality implementation of the School Health Policy plays crucial role in developing knowledgeable and skillful human resource with good health. School Health Policy implementation cannot be successful without involvement and support from relevant stakeholders. School Health Policy helps ensure equitable and inclusive access to health education services.

However, gaps are still observable in implementing the policy because of the Lack of human resource in school health, inadequate legal documents, material and monetary resources, good coordination, policy dissemination, and particularly the stakeholder's involvement has yet meet the expectation.

To tackle this issue, the Royal Government of Cambodia via the Ministry of Education, Youth and Sport, has developed Education Strategic Plan, many other policies and action plans to ensure a successful implementation of the School Health Policy. This requires consistent multi-sector involvements, development of legislation documents preparation of project for school health promotion in educational institutions, preparation of health infrastructure develop of school model in health and hygiene and environment. To build human capital in school health, additional financial support by mobilizing all stakeholders, Ministries, institutions, national and international organization, development partners, civil